ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សំណុំរឿងរដ្ឋប្បវេណី
លេខ ១១៧៤
ចុះថ្ងៃទី០២-០៨-២០១១
-សាលក្រមរដ្ឋប្បវេណី
លេខ ៤៥"ឃ"
ចុះថ្ងៃទី៣០ ខែកក្កដា
ឆ្នាំ២០១២

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១២ លើសំណុំរឿងរដ្ឋប្បវេណីលេខ ១១៧៤ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១១ ដោយមានសមាសភាពដូចតទៅ ៖

**ចៅក្រមជំនុំជម្រះ**

- លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

- លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-រវាងដើមចោទឈ្មោះ [redacted] ណារឿន ភេទប្រុស អាយុ៤៧ឆ្នាំ ជាតិខ្មែរ មុខរបរ គ្មាន ទីលំនៅសព្វថ្ងៃផ្ទះលេខ ០៨Eo ផ្លូវលំ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ទីវ"ស" ម្ដាយឈ្មោះ [redacted] ណយ"ស" ប្រពន្ធឈ្មោះ [redacted] ស្រីវត្ត មានកូន ០២នាក់ ។

លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ

-និងចុងចម្លើយឈ្មោះ [redacted] ស្រីវត្ត ភេទស្រី អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរ កម្មករ ទីលំនៅសព្វថ្ងៃផ្ទះលេខ ០៨Eo ផ្លូវលំ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] វិន"ស" ម្ដាយឈ្មោះ [redacted] ទូច"រ" ប្ដីឈ្មោះ [redacted] ណារឿន មានកូន ០២នាក់ ។

លោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិ

**កម្មវត្ថុបណ្ដឹង:**

-ឈប់រស់នៅជាអនីតិសង្វាស
-បែងចែកទ្រព្យសម្បត្តិរួម
-គ្រប់គ្រងទ្រព្យសម្បត្តិដោយឡែក
-គ្រប់គ្រងកូន

### អង្គហេតុនិងចំណុចវិវាទ

### ១-សាលក្រមដែលទាមទារដោយភាគី

-ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទសុំ៖

-ទាមទារឈប់រស់នៅជាអនីតិសង្វាសពីប្រពន្ធឈ្មោះ [redacted] ស្រីវត្ត

-ទាមទារបែងចែកទ្រព្យសម្បត្តិរួម៖

ក/-ដីស្រែទំហំ ២០១៦ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រាវអែម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ។

ខ/ដីស្រែទំហំ ២២១៤ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រាវអែម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ។

-ទាមទារសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិដោយឡែក នូវផ្ទះលេខ ០៨E០ ផ្លូវលំ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ទំហំ ៤ម៉ែត្រ គុណ ១៦ម៉ែត្រ ស្មើ ៦៤ម៉ែត្រការ៉េ ។

-ទាមទារសិទ្ធិគ្រប់គ្រងកូនទាំងពីរនាក់៖

១-ឈ្មោះ [redacted] វ័ឌ្ឍដារូ ភេទស្រី កើតថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥ ។

២-ឈ្មោះ [redacted] វ័ឌ្ឍដាណា ភេទស្រី កើតថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩ ។

-ចម្លើយតបរបស់ចុងចម្លើយ

-ឯកភាពឈប់រស់នៅជាអនីតិសង្វាសពីឈ្មោះ [redacted] ណារឿន ។

-ទាមទារបែងចែកទ្រព្យសម្បត្តិរួម៖

ក/ដីស្រែទំហំ ២២១៤ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រាវអែម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ។

ខ/ផ្ទះលេខ ០៨E០ ផ្លូវលំ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ទំហំ ៤ម៉ែត្រ គុណ ១៦ម៉ែត្រ ស្មើ ៦៤ម៉ែត្រ ការ៉េ ។

គ/រថយន្តមួយគ្រឿងម៉ាក Camery ឆ្នាម មួយគ្រឿង ។

-ទាមទារសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិដោយឡែក នូវដីស្រែទំហំ ២០១៦ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រាវអែម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ។

-ទាមទារសិទ្ធិគ្រប់គ្រងកូនទាំងពីរនាក់៖

១-ឈ្មោះ [redacted] វ័ឌ្ឍដារូ ភេទស្រី កើតថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥ ។

២-ឈ្មោះ [redacted] វ័ឌ្ឍដាណា ភេទស្រី កើតថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩ ។

-ទាមទារអាហារកិច្ចចិញ្ចឹមកូនទាំងពីរផ្តាច់ចំនួន ២០.០០០$US(ពីរម៉ឺនដុល្លារអាមេរិក) ។

## ២-ការពន្យល់ត្រួសៗអំពីរឿងក្តី ៖

ដើមចោទឈ្មោះ [redacted] ណារឿន បានអះអាងថា ខ្លួនបានរៀបការជាមួយឈ្មោះ [redacted] ស្រីវ័ឌ្ឍ តាំងពីថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៤ គឺពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ទេ ។ ខ្លួនប្តឹងសុំឈប់រស់នៅជាអនីតិសង្វាសពីឈ្មោះ [redacted] ស្រីវ័ឌ្ឍ ដោយមូលហេតុថាៈ ប្រពន្ធខ្លួនដើរលេងពេលយប់តាមទំនើងចិត្ត ប្រព្រឹត្តលេងល្បែងស៊ីសងឈ្លោះប្រកែកគ្នាជាញឹកញាប់ ធ្វើអ្វីៗស្រេចតែចិត្តមិនស្តាប់បង្គាប់របស់ខ្លួនទេ គឺបានស្ម័គ្រចិត្តលែងលះគ្នា ដូចតាមកិច្ចសន្យាលែងលះគ្នាដោយស្ម័គ្រចិត្ត កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៧ គឺបានបែកលំនៅសង្វាសពីគ្នាប្រហែលពីរឆ្នាំ ។ បន្ទាប់មកខ្លួនបានទិញផ្ទះលេខ ០៨E០ ផ្លូវលំ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដើម្បីរស់នៅម្នាក់ឯង ដែលជាទ្រព្យសម្បត្តិដោយឡែកក្រោយពេលលែងលះគ្នាកន្លងមក ។ លុះក្រោយមកនៅចុងឆ្នាំ២០០៩ប្រពន្ធរបស់ខ្លួនបានមកសុំស្រុះស្រួលវិញ គឺបានទិញដីស្រែចំនួនពីរកន្លែងនៅខេត្តតាកែវ ដែលមានទំហំ ២០១៦ម៉ែត្រការ៉េ ស្ថិតនៅភូមិ ត្រាវអែម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ និង ទំហំ ២២១៤ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រាវអែម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ គឺជាទ្រព្យសម្បត្តិរួម ខ្លួនសុំបែងចែកជាពីរចំណែកស្មើគ្នា ។ ខ្លួនមានកូនពីរនាក់ឈ្មោះ [redacted] វ័ឌ្ឍដារូ ភេទស្រី កើតថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥ និងឈ្មោះ [redacted] វ័ឌ្ឍដាណា ភេទស្រី កើតថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩ សុំសិទ្ធិគ្រប់គ្រងមិនទាមទារអាហារកិច្ចចិញ្ចឹមកូនទេ បើមិនដូច្នេះទេសុំផ្តល់អាហារកិច្ចចិញ្ចឹមកូនតាម



Scanned with CamScanner

លទ្ធភាពចំនួន ៨០០០០រៀល(ប្រាំបីម៉ឺនរៀល) ក្នុងមួយខែនៃកូនម្នាក់ៗ ព្រោះខ្លួនជាមន្ត្រីចូលនិវត្តន៍គ្មានការងារធ្វើ និងគ្មានមុខរបរ ។ បំណុលអ្នកដំខែគ្មានទេ ។

-ចុងចម្លើយឈ្មោះ [redacted] ស្រីវ័ន្ត បានអះអាងថា៖ ខ្លួនឯកភាពឈប់រស់នៅជាអនីតិសង្វាសពីដើមចោទឈ្មោះ [redacted] ណារឿន មិនជំទាស់អ្វីទេ ព្រោះយល់ឃើញថាតែងតែមានទំនាស់និងគ្នាតែបានលែងលះគ្នាដូចតាមលិខិតកិច្ចសន្យាលែងលះគ្នាដោយស្ម័គ្រចិត្តម្តងរួចមកហើយ កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៧ ។ បន្ទាប់មកនៅឆ្នាំ២០០៩ និងឆ្នាំ២០១០ បានស្រុះស្រួលគ្នាវិញ ហើយក៏ឈ្លោះប្រកែកគ្នាបន្តទៀត គឺកាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ ឈ្មោះ[redacted] ណារឿន បានចុះចោលផ្ទះ ចុះចោលលំនៅសង្វាសពីគ្នារហូតមក ។ ទ្រព្យសម្បត្តិរួមមាន៖ ផ្ទះលេខ ០៩E០ ផ្លូវលំ ភូមិព្រៃព្រីង ខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ. ដីស្រែទំហំ ២២១៤ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រាវអែម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ និងរថយន្តម៉ាក Camery ចំនួនមួយគ្រឿង សុំបែងចែកជាពីរចំណែកស្មើគ្នា ។ ចំណែកដីស្រែទំហំ ២០១៦ម៉ែត្រការ៉េ ស្ថិតនៅភូមិ ត្រាវអែម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ គឺជាទ្រព្យសម្បត្តិកេរ្តិ៍មរតករបស់ម្តាយខ្លួនចែកមកឱ្យខ្លួនតែម្នាក់ឯង ដែលជាទ្រព្យសម្បត្តិដោយឡែក ។ ខ្លួនមានកូនពីរនាក់ ឈ្មោះ [redacted] រ័ត្នដារ៉ានូ និងឈ្មោះ [redacted] រ័ត្នដាណា សុំសិទ្ធគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សា និងសុំទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនផ្តាច់ចំនួន ២០០០០$US (ពីរម៉ឺនដុល្លារអាមេរិក) គឺមិនអាចទទួលយកអាហារកិច្ចចិញ្ចឹមកូនម្នាក់ៗចំនួន ៨០០០០រៀល (ប្រាំបីម៉ឺនរៀល)- ក្នុងមួយខែបានទេ ។ បំណុលអ្នដំខែគ្មាន ។

## ៣-ចំណុចវិវាទ

ចំណុចវិវាទនៅក្នុងសំណុំរឿងនេះគឺ៖

-ថាតើទ្រព្យសម្បត្តិដោយឡែកនៃភាគីនីមួយៗលើកឡើង អាចឱ្យតុលាការសម្រេចបែងចែកជាពីរចំណែកស្មើគ្នាបានដែរឬទេ ?

-ថាតើទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែកដែលភាគីនីមួយៗលើកឡើង សុទ្ធតែជាទ្រព្យសម្បត្តិរួមចំណងអាពាហ៍ពិពាហ៍ ពិតប្រាកដមែនឬទេ ?

-ថាតើសិទ្ធិនៃការគ្រប់គ្រងកូន ត្រូវផ្តល់ជូនឱ្យភាគីណាមួយ?

-ថាតើតម្រូវឱ្យភាគីមិនបានគ្រប់គ្រងកូនត្រូវប្រគល់អាហារកិច្ចចិញ្ចឹមកូនក្នុងកម្រិតណា?

## សំអាងហេតុ

-ដើមចោទ និងចុងចម្លើយបានរៀបការជាមួយគ្នាកាលពីថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៤ គឺពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ទេ ។ ប៉ុន្តែគូភាគីមានសៀវភៅគ្រួសារលេខ ០៥ក្រក ២៨៦២៨ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៧ និងលិខិតបញ្ជាក់របស់មេភូមិលោក[redacted] គង់ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១១ បញ្ជាក់ថាជាប្តីប្រពន្ធនឹងគ្នា រស់នៅបែបអនីតិសង្វាស ។

-ដើមចោទបានប្តឹងទាមទារឈប់រស់នៅជាអនីតិសង្វាសពីចុងចម្លើយដោយមូលហេតុថា ភាគីចុងចម្លើយបានប្រព្រឹត្តលេងល្បែងស៊ីសង និងដើរលេងរាល់ៗយប់តាមទំនើងចិត្ត ដោយមិនស្តាប់តាមដើមចោទបានហាមនឹងធ្លាប់មានទំនាស់លែងលះគ្នាដូចតាមកិច្ចសន្យាលែងលះគ្នាដោយស្ម័គ្រចិត្ត ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៧ ម្តងរួចមកហើយ ក្រោយមកនៅចុងឆ្នាំ២០០៩ក៏ស្រុះស្រួលគ្នាវិញ តែភាគីនៅតែរស់នៅមិនចុះសម្រុងនឹងគ្នាដដែល គឺបានឈ្លោះគ្នាឡើងវិញ ព្រមទាំងបែកលំនៅសង្វាសពីគ្នាតាំងពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ រហូតមក ហើយ



Scanned with CamScanner

ចុងចម្លើយ បានឯកភាពឈប់រស់នៅជាអធិតិសង្វាសពីដើមចោទ ។ ឆ្លងតាមការផ្សះផ្សាជាច្រើនលើកឃើញថា ភាគីពិតជារស់មនោសញ្ចេតនាជាប្តីប្រពន្ធ ដែលអាចឱ្យតុលាការសម្រេចឱ្យឈប់រស់នៅជាអធិតិសង្វាសតាមការព្រមព្រៀង តាមមាត្រា ៩៧៨ ក្នុងកថាខណ្ឌទី១ ចំណុចង និងមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី ។

-ដើមចោទ និងចុងចម្លើយទទួលស្គាល់ថា មានកូន០២នាក់ ឈ្មោះ [redacted] រ័ត្នដាន្ទ ភេទស្រី កើតថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥ ដោយមានសំបុត្រកំណើតលេខ ១៥៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១០ និងឈ្មោះ [redacted] រ័ត្នដាណា ភេទស្រី កើតថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩ ដោយមានសំបុត្រកំណើតលេខ ១៥៨ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១០ ជាសំអាង ។ នៅដំណាក់កាលត្រៀមសម្រាប់ការទាញហេតុផល និងពេលទាញហេតុផលដោយផ្ទាល់មាត់ ភាគីនៅតែទាមទារសិទ្ធិគ្រប់គ្រងកូនតែរៀងៗខ្លួន ដូចនេះតុលាការនឹងលើកយកមកពិចារណាលើសមត្ថភាព ភាគីដើមចោទ ឬភាគីចុងចម្លើយដែលមានលទ្ធភាពនឹងទទួលបាននូវសិទ្ធិគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សាកូនបានល្អជាង ដើម្បីជាអត្ថប្រយោជន៍នៃអនាគតដែលជាកូនៗរបស់ភាគី ជាក់ស្តែងកូនទាំងពីរនាក់ទើបតែមានវ័យអាយុត្រឹមតែ០៧ឆ្នាំ និង០៣ឆ្នាំ ដែលបច្ចុប្បន្នរស់នៅជាមួយភាគីចុងចម្លើយ ។ ចំណែកអាហារកិច្ចចិញ្ចឹមកូន គប្បីតុលាការសម្រេចតាមលទ្ធភាព ដើម្បីឱ្យភាគីដែលមិនបានទទួលសិទ្ធិគ្រប់គ្រងកូន ត្រូវតែបំពេញករណីកិច្ចផ្គត់ផ្គង់ចិញ្ចឹមកូនរហូតដល់វ័យនីតិភាព ។

-ដើមចោទបានអះអាងចំពោះទ្រព្យសម្បត្តិរួមនិងទ្រព្យសម្បត្តិដោយឡែកថាៈ ក្រោយពីពេលរៀបការរួចមកតាំងពីថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៤ ដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៧ បានលែងលះគ្នាម្តងដូចមានកិច្ចសន្យាលែងលះគ្នាដោយស្ម័គ្រចិត្ត ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៧ គឺគ្មានទ្រព្យសម្បត្តិរួមជាមួយគ្នាទេ ។ បន្ទាប់មកដើមចោទបានទិញផ្ទះលេខ ០៨E₀ ផ្លូវលំ ភូមិព្រៃព្រីង ខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដាក់ឈ្មោះតែម្នាក់ឯងដើម្បីរស់នៅដូចតាមលិខិតផ្ទេរសិទ្ធិកាន់កាប់ដី-ផ្ទះ លេខ ១៥១១ បជ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៩ ជាភស្តុតាង ថាជាទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទ ។ លុះក្រោយមកទៀតចុងចម្លើយក៏បានទទួលស្គាល់ថា នៅឆ្នាំ២០០៩ និងឆ្នាំ២០១០ បានស្រុះស្រួលរួមរស់ជាមួយគ្នាជាប្តីប្រពន្ធបន្តទៀត ដែលដើមចោទក៏បានទទួលស្គាល់ថា បានទិញដីស្រែទំហំ ២០១៦ម៉ែត្រការ៉េ ស្ថិតនៅ ភូមិត្រាវអែម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ដូចតាមលិខិតបញ្ជាក់សុំកាន់កាប់ប្រើប្រាស់ដីលេខ ៤៣០/០៩ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៩ និងដីស្រែទំហំ ២២១៤ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រាវអែម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ដូចតាមលិខិតទិញនិងលក់ដីលេខ ០៧៧/១០ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១០ មានដាក់ឈ្មោះទាំងពីរនាក់ គឺជាទ្រព្យសម្បត្តិរួមដែលមានចាប់ពីចុងឆ្នាំ២០០៩ រហូតដល់ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ ដែលត្រូវបានឈប់រស់នៅជាមួយគ្នា និងបានបែកលំនៅសង្វាសពីគ្នារហូតដល់ពេលបច្ចុប្បន្ននេះ ជាភស្តុតាង ។

-ចុងចម្លើយឈ្មោះ [redacted] ស្រីរ័ត្ន បានអះអាងចំពោះទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែកថាៈ ចាប់ពីថ្ងៃរៀបការ តាំងពីថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៤ រហូតដល់ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ ដែលបានឈប់រស់នៅជាមួយគ្នាជាលើកទី២ ប្តីប្រពន្ធរបស់ខ្លួនមានទ្រព្យសម្បត្តិរួម គឺផ្ទះលេខ ០៨E₀ ផ្លូវលំ ភូមិព្រៃព្រីង ខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលឈ្មោះ [redacted] ណារឿន បានលួចលាក់ទៅទិញដាក់ឈ្មោះតែម្នាក់ឯង រីឯដីស្រែទំហំ ២២១៤ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រាវអែម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ គឺបានទៅទិញទាំងអស់គ្នា ដាក់ឈ្មោះទាំងពីរនាក់ ដែលដើមចោទទទួលស្គាល់ផងដែរ ។ ចំពោះដីស្រែទំហំ ២០១៦ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រាវអែម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ គឺជាដីកេរ្តិ៍មរតករបស់ម្តាយបង្កើតដែលបានចែកមកឱ្យចុងចម្លើយ ដូចតាមលិខិតបញ្ជាក់សុំកាន់កាប់ប្រើប្រាស់ដីលេខ ៤៣០/០៩ ចុះថ្ងៃទី១៣

៣៤៣
343

ខែធ្នូ ឆ្នាំ២០០៩ មានឈ្មោះ [redacted] ទូច ជាម្ដាយបានដឹងឮជាសាក្សី ជាភស្តុតាង ថាជាទ្រព្យសម្បត្តិដោយឡែករបស់ចុងចម្លើយ ហេតុនេះគប្បីប្រគល់ឱ្យចុងចម្លើយវិញ រីឯទ្រព្យសម្បត្តិផ្សេងពីនេះចែកគ្នាតាមច្បាប់ ។

-រាល់ឯកសារភស្តុតាងដែលទាក់ទិនទៅនឹង ទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែក ព្រមទាំងចម្លើយអះអាងរបស់គូភាគីខាងលើ ឃើញថា ដីស្រែទំហំ ២២១៤ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រាវអែម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ បានឯកភាពគ្នាទទួលស្គាល់ថាជាទ្រព្យសម្បត្តិរួម ។

-តាមការអះអាងរបស់ដើមចោទថាៈ ផ្ទះលេខ ០៨E₀ ផ្លូវលំ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ គឺជាទ្រព្យសម្បត្តិដោយឡែក ចំណែកចុងចម្លើយអះអាងថា ដីស្រែទំហំ ២០១៦ម៉ែត្រការ៉េ ស្ថិតនៅ ភូមិត្រាវអែម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ គឺជាទ្រព្យសម្បត្តិដោយឡែកដែលគប្បីនេះគប្បីតុលាការពិនិត្យ និងសម្រេចតាមច្បាប់ ។

-ម្យ៉ាងវិញទៀត ចុងចម្លើយបានលើកយកទ្រព្យសម្បត្តិរួមមាន រថយន្តម៉ាក Camery ចំនួន មួយគ្រឿងថែមទៀត យកមកឱ្យតុលាការបែងចែកឱ្យដែរ តែពុំមានភស្តុតាងជូនដល់តុលាការទេ ចំណុចនេះមិនលើកយកមកពិចារណាឡើយ ។

-ដើមចោទ និងចុងចម្លើយបានទទួលស្គាល់ថា ពុំមានជំពាក់បំណុលអ្នកដទៃទេ ។ ដូចនេះ តុលាការពុំពិចារណាលើកគ្គានេះឡើយ ។

## សេចក្ដីសម្រេចបញ្ចប់

១-ទទួលស្គាល់ការសុំឈប់រស់នៅលក្ខណៈជាប្ដីប្រពន្ធបែប អនីតិសង្វាសរវាងឈ្មោះ [redacted] ណារឿន ភេទប្រុស អាយុ៥៧ឆ្នាំ និងឈ្មោះ [redacted] ស្រីវ័ន្ត ភេទស្រី អាយុ២៨ឆ្នាំ ចាប់ពីពេលនេះតទៅ តាមការព្រមព្រៀងរបស់គូភាគី ។

២-ប្រគល់កូនពីរនាក់គឺឈ្មោះ ឈ្មោះ [redacted] វ័ន្តដានូ ភេទស្រី កើតថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥ និងឈ្មោះ [redacted] វ័ន្តដាណា ភេទស្រី កើតថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩ ឱ្យភាគីចុងចម្លើយឈ្មោះ [redacted] ស្រីវ័ន្ត ជាម្ដាយទទួលសិទ្ធិគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សា មើលការខុសត្រូវអប់រំឱ្យរៀនសូត្រមានអនាគតល្អ ដោយឱ្យដើមចោទឈ្មោះ [redacted] ណារឿន ជាឪពុកជួយចេញអាហារកិច្ចចិញ្ចឹមកូនៗទាំងពីរនាក់ចំនួន ១០០០០០រៀល (ដប់ម៉ឺនរៀល) ក្នុងមួយខែឱ្យចុងចម្លើយ គិតចាប់ពីថ្ងៃប្រកាសសាលក្រម- គឺថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ រហូតដល់កូនៗមាននីតិភាព ។

៣-ឱ្យភាគីចុងចម្លើយជាអ្នកមានអំណាចមេបាលើកូន បង្ករលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ភាគីដើមចោទ ជាឪពុកមានលទ្ធភាពគ្រប់គ្រាន់ទៅមកសាកសួរសុខទុក្ខកូនៗគ្រប់ពេលវេលា ។

៤-អំពីទ្រព្យសម្បត្តិរួមមាន៖

ក/ទ្រព្យសម្បត្តិកម្មសិទ្ធិដោយឡែករបស់ដើមចោទឈ្មោះ [redacted] សារឿន គឺផ្ទះលេខ ០៨E₀ ផ្លូវលំ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ តាមលិខិតផ្ទេរសិទ្ធិកាន់កាប់ដី-ផ្ទះលេខ ១៥១១ បជ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៩ ត្រូវប្រគល់ឱ្យដើមចោទ ទទួលសិទ្ធិកាន់កាប់គ្រប់គ្រងជាម្ចាស់កម្មសិទ្ធិតាមច្បាប់តទៅ ។

ខ/ដីស្រែទំហំ ២០១៦ម៉ែត្រការ៉េ ស្ថិតនៅ ភូមិត្រាវអែម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ម្ចាស់កម្មសិទ្ធិឈ្មោះ [redacted] ណារឿន និងឈ្មោះ [redacted] ស្រីវ័ន្ត តាមលិខិតបញ្ជាក់សុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ

៣៤៤



Scanned with CamScanner

៤៣០/០៩ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៩ របស់ប្រធានឃុំពពេល ត្រូវប្រគល់ឱ្យភាគីចុងចម្លើយឈ្មោះ [redacted] ស្រីរ័ត្ន ទទួលសិទ្ធិកាន់កាប់គ្រប់គ្រងជាម្ចាស់កម្មសិទ្ធិតាមច្បាប់តទៅ ។

———ដីស្រែប្រវែងបណ្ដោយ ៥១.៥០ម និងទទឹងប្រវែង ៤៣ម (២២១៤ម៉ែត្រការ៉េ) ស្ថិតនៅភូមិត្រាវអែម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានម្ចាស់កម្មសិទ្ធិឈ្មោះ [redacted] ណារឿន និងឈ្មោះ [redacted] ស្រីរ័ត្ន តាមលិខិតទិញ និងលក់ដីលេខ ០៧៧/១០ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១០ របស់មេឃុំពពេល គឺត្រូវបែងចែកជាពីរចំណែក ស្មើៗគ្នា រវាងគូភាគី ។

ការប្ដឹងទាមទារបែងចែកទ្រព្យសម្បត្តិរួមក្រៅពីចំណុចដូចខាងលើ គ្មានភស្តុតាងបញ្ជាក់ តុលាការមិនលើកមកពិចារណានិងសម្រេចទេ ។

៥-សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១២ ចំពោះមុខដើមចោទ និងចុងចម្លើយ ព្រមទាំងមេធាវីតំណាងដោយអាណត្តិ និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ ចំពោះមុខដើមចោទនិងចុងចម្លើយ ព្រមទាំងមេធាវីតំណាងដោយអាណត្តិ ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ភ្នំពេញ ថ្ងៃទី០៩ ខែ សីហា ឆ្នាំ២០១២

ក្រឡាបញ្ជី

[redacted]

**បានឃើញ**

ចៅក្រមជំនុំជម្រះ

[redacted]

៣៤៥

345